




## សម្រាប់ការផ្សព្វផ្សាយ

**សន្និសីទសារព័ត៌មាន៖ រថយន្តតន្ត្រីទិព្វខ្មែរ នឹងក្លាយជាកម្មវិធីមួយរបស់ “ អង្គការសិល្បៈខ្មែរអមតៈ ” ចាប់តាំងពីពេលនេះតទៅ។**

***សន្និសីទធ្វើនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៨ ម៉ោង ១០ - ១១ ព្រឹក***

**ភ្នំពេញ, ២៣ មករា ២០១៨ - រថយន្តតន្ត្រីទិព្វខ្មែរ** នឹងក្លាយជាកម្មវិធីមួយរបស់ **អង្គការសិល្បៈខ្មែរអមតៈ** ចាប់ពីពេលនេះតទៅ។ ការចូលរួមនេះ នឹងធ្វើឲ្យរថយន្តតន្ត្រីទិព្វខ្មែរកាន់តែមានសមត្ថភាពពេញលេញក្នុងការនាំទម្រង់សិល្បៈខ្មែរកម្រៗទៅផ្សព្វផ្សាយ និងសម្តែងទូទាំងប្រទេសកម្ពុជាកាន់តែច្រើនជាងមុន ក៏ដូចជាអភិរក្សទម្រង់សិល្បៈទាំងនោះឲ្យគង់វង្សបិតថេរសម្រាប់កូនខ្មែរជំនាន់ក្រោយផងដែរ។ ជាពិសេសគម្រោងថ្មីៗរបស់ខ្លួនដូចជាការផលិតឧបករណ៍ភ្លេង និងការឧបត្ថម្ភសកម្មភាពសិល្បករនៅសហគមន៍ចំនួនពីរនៅអារ៉េង និងឧត្តរមានជ័យ។

បង្កើតឡើងនៅចុងឆ្នាំ២០១៣ **រថយន្តតន្ត្រីទិព្វខ្មែរ** មានបេសកកម្មរក្សាទម្រង់សិល្បៈកម្រៗរបស់ខ្មែរឲ្យនៅតែមានសកម្មភាព។ ជាមួយនឹងរថយន្តធំមួយគ្រឿង ពួកគេបានដឹកនាំសិល្បករ ចុះទៅធ្វើបទបង្ហាញ និងសម្តែងទម្រង់សិល្បៈខ្មែរដូចជា គែន ទ្រខ្សែបី ចាប៉ីដងវែង ខ្សែដៀវ វង់ភ្លេងស្គរថូន ភ្លយ និងឧបករណ៍ផ្លុំផ្សេងៗទៀតនៅតាមភូមិ និងសហគមន៍ទូទាំងប្រទេស។ រហូតមកដល់ពេលនេះ រថយន្តតន្ត្រីទិព្វខ្មែរ បានរៀបចំការប្រគំតន្ត្រីធំៗ៣០ដង និងសកម្មភាពសិល្បៈរយៈពេលខ្លីជាច្រើននានា។

គួរបញ្ជាក់ដែរថា **សិល្បៈខ្មែរអមតៈ** ជាដៃគូរបស់រថយន្តតន្ត្រីទិព្វខ្មែរ គឺជាអង្គការមានបទពិសោធន៍ក្នុងវិស័យសិល្បៈ និងវប្បធម៌នៅកម្ពុជារយៈពេល២០ឆ្នាំមកហើយ។ ក្នុងតួនាទីជាកត្តាលិករ ជំរុញការលូតលាស់នៃវិស័យនេះ សិល្បៈខ្មែរអមតៈបានធ្វើការងារជាច្រើនរួមមាន ការផ្តល់អាហារូបករណ៍ មូលនិធិខ្នាតតូចដល់សិល្បករ ឱកាសសម្តែង ការផ្លាស់ប្តូរទស្សនកិច្ច និងការអប់រំសិល្បៈនៅតាមសាលា។ ពិសេស យើងទាំងពីរមានប្រវត្តិរួមគ្នា គឺបង្កើតឡើងដោយស្ថាបនិកតែមួយ លោក អាន ចន-ផន និងមានសកម្មភាពប្រហាក់ប្រហែលគ្នា។

ដោយសារយើងមានចក្ខុវិស័យដូចគ្នាគឺ សិល្បៈ និងវប្បធម៌មានសារៈសំខាន់ដែលមិនអាចខ្វះបានសម្រាប់អនាគតដ៏រុងរឿងរបស់កម្ពុជា ទើបភាគីទាំងពីរបានចុះកិច្ចព្រមព្រៀងគ្នាមួយដោយ **សិល្បៈខ្មែរអមតៈ** នឹងជួយ **រថយន្តតន្ត្រីទិព្វខ្មែរ** ក្នុងការអភិវឌ្ឍសមត្ថភាពគ្រប់គ្រងការងារ ការរៀបចំផែនការហិរញ្ញវត្ថុ និងកិច្ចការរដ្ឋបាល ព្រមទាំងជួយឲ្យកម្មវិធីនេះ អាចបង្កើនទំនាក់ទំនង និងការសម្តែងកាន់តែច្រើនឡើង។ កាន់តែពិសេស យើងនឹងធ្វើការរួមគ្នាលើការអនុវត្តបច្ចេកវិទ្យាទំនើប (កាមេរ៉ា ៣៦០) ក្នុងការរក្សាទុក និងផ្សព្វផ្សាយអំពីទម្រង់សិល្បៈ និងឧបករណ៍ភ្លេងកម្រៗផងដែរ។ តាមរយៈការងារទាំងនេះ យើងជឿជាក់ថា **រថយន្តតន្ត្រីទិព្វខ្មែរ** នឹងអាចរក្សាបេសកម្មរបស់ខ្លួនប្រកបដោយនិរន្តរភាព និងពេញលេញក្នុងរយៈពេលវែង។

យើងខ្ញុំសូមស្វាគមន៍លោក-លោកស្រី ចូលរួមសន្និសីទនេះដោយមេត្រី។

កាលបរិច្ឆេទ៖ ថ្ងៃព្រហស្បតិ៍ ទី២៥ ខែមករា ឆ្នាំ២០១៨
ចាប់ពីម៉ោង ១០ ដល់ ១១ព្រឹក, សន្និសីទ និងការសម្តែង
ទីតាំង៖ ឆាកសម្តែងសិល្បៈខ្មែរអមតៈ បរិវេណសារមន្ទីរជាតិ, ភ្នំពេញ

សម្រាប់ការចូលរួម សូមទាក់ទងមក sokim@cambodianlivingarts.org ឬទាក់ទងទូរស័ព្ទលេខ 011 460 900 / 070 596 076។

---

**កំណត់ចំណាំសម្រាប់អ្នកនិពន្ធ**

**អង្គការសិល្បៈខ្មែរអមតៈ**

អង្គការសិល្បៈខ្មែរអមតៈ មានបេសកកម្មដើរតួជាកត្តាជំរុញក្នុងវិស័យសិល្បៈដ៏រស់រវើក ដែលញ៉ាំងចិត្តអ្នកជំនាន់ថ្មី។ បង្កើតឡើងក្នុងឆ្នាំ១៩៩៨ ដោយលោក អាន ចនផន ជាតន្ត្រីករដែលនៅរស់រានមានជីវិតពីសម័យប៉ុល ពត ហើយក៏ជាអ្នកការពារសន្តិភាពមួយរូបផងដែរ។ ដំបូងពួកគេផ្តោតសំខាន់លើការការពារសិល្បៈទស្សនីយភាពដែលកំពុងមានការគំរាមកំហែង។ រយៈពេល២ ទសវត្សក្រោយមកពួកគេបានអភិវឌ្ឍការងារដោយបង្កើតឲ្យមានឱកាសអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ការផ្លាស់ប្តូរវប្បធម៌ ការស្រាវជ្រាវ និងការបង្កើតបណ្តាញជាអន្តរជាតិ។ ហើយក៏បានផ្តល់ឱកាសការងារដល់សិល្បករតាមរយៈការសម្តែងជាប្រចាំ និងការបង្កើតមហោស្រពផ្សេងៗ។ នៅពេលខាងមុខ អង្គការសិល្បៈខ្មែរអមតៈនឹងផ្តោតលើការយកចិត្តទុកដាក់បន្ថែមលើការបង្កើត និងការច្នៃប្រឌិតក្នុងវិស័យសិល្បៈ និងកសាងទំនាក់ទំនងក្នុងវិស័យសិល្បៈទាំងក្នុង និងក្រៅប្រទេសផងដែរ។ ពួកគេកំពុងតែធ្វើការដាក់បញ្ចូលកម្មវិធីអប់រំសិល្បៈ និងវប្បធម៌ទៅក្នុងកម្មវិធីសិក្សារដ្ឋ និងបង្កើនឱកាសសម្តែងដល់សិល្បករកម្ពុជាផងដែរ។
www.cambodianlivingarts.org

Connect with us